ប្រតិកម្មរហ័ស

## ការរំលោភអំណាច និង ការរំលោភឆន្ទៈប្រជាពលរដ្ឋ

ការបង្ក្រាបអ្នកប្រឆាំងមតិ, ប្រឆាំងនយោបាយ ។ល។ ដោយយកប្រព័ន្ធតុលាការជាមធ្យោបាយ វាជាធម្មជាតិ នៃរបបផ្តាច់ការ យកអាវុលទ្ធិប្រជាធិបតេយ្យមកពាក់។ ដូចយើងបានដឹងស្រាប់រួចមកហើយថា របបនយោបាយនៅស្រុកខ្មែរបច្ចុប្បន្ន វាមានលក្ខណៈបែបនេះ ហើយតែងតែប្រើមធ្យោបាយបែបនេះជានិច្ច ដូច្នេះការបង្ក្រាប ដោយមានការចាប់ឃុំឃាំងអ្នកប្រឆាំងនយោបាយ នៅថ្ងៃទី១៥កក្កដាថ្មីៗនេះ ជាទង្វើមួយ ក្លាយជាទំលាប់នៅក្នុងជីវិតនយោបាយខ្មែរតាំងពីឆ្នាំ១៩៩៣មកម្លេះ។ ក្រោយពីការបោះឆ្នោតថ្នាក់ជាតិនិមួយៗ គណបក្សប្រឆាំង តែងតែចូលរួមពង្រឹងជានិច្ចគ្រឹះរបបផ្តាច់ការនេះ តាមការចូលធ្វើសហប្រតិបត្តិការ, តាមការប្រកាន់យកអាកប្បកិរិយាអកម្ម នៅចំពោះមុខការប្រព្រឹត្តស្តែង គ្រប់អំពើឥតស្របច្បាប់ របស់អ្នកកាន់អំណាចផ្តាច់ការ ហើយបច្ចុប្បន្ននេះ បន្តធ្វើការចរចារជាមួយគណបក្សកាន់អំណាចឥតស្របច្បាប់នេះ ក្នុងឋានៈជាអ្នកចាញ់ឆ្នោតថែមទៀត។ ការដាក់ត្រួតនៃអំពើអវិជ្ជមាន ទាំងឡាយនេះជាងម្ភៃមកហើយ (១៩៩៣-២០១៤) វាជាការហុចថ្នាំកម្លាំងឲគណបក្សកាន់អំណាចផឹក សំរាប់ពង្រឹងសាច់ដុំវា ឲកាន់តែរឹងប៉ឹង ដើម្បីស្រួលវ៉ៃតប់អ្នកប្រឆាំង កាន់តែពូកែទៅទៀត។ ក្នុងស្ថានភាពបែបនេះ នាំឲគណបក្សប្រឆាំង ដែលគ្រាន់តែតាំងខ្លួន (soi-disant) ឬ ប្រឆាំងតែមាត់ ឋិតនៅក្នុងជំហរការពារខ្លួនជានិច្ច គ្មានលទ្ធភាព មានដើមគំនិត ឬ ប្រកាន់ជំហរវាយលុកនយោបាយប្រឆាំងនឹងរបបផ្តាច់ការនោះឡើយ ប៉ុន្តែគណបក្សប្រឆាំងធ្លាប់មានឱកាសច្រើនដងណាស់ ដើម្បីពុះពារប្រឆាំងទល់នឹងរបបផ្តាច់ការ ដូចយ៉ាងមានកើតមហាបាតុកម្មក្រោយពីការបោះឆ្នោតថ្នាក់ជាតិក្នុងឆ្នាំ២០១៣ដែលទើបតែកន្លងផុតទៅនេះ។

បច្ចុប្បន្ននេះ ដំណើរខឹងច្រឡោត (emportement) របស់ប្រជាជនខ្មែរ ប្រឆាំងនឹងអំពើអយុត្តធម៌ (លួចសន្លឹកឆ្នោតពីសំណាក់គណបក្សកាន់អំណាច ដើម្បីប្រកាសជាអ្នកឈ្នះឆ្នោត)

ត្រូវគណបក្សប្រឆាំងតែមាត់ បង្រួមឲតូចបំផុតនៅត្រឹមតែ ឧបករណ៍របស់ខ្លួនទៅសុំចរចារ ជាមួយគណបក្សកាន់អំណាច ដើម្បីចែកអំណាចតែប៉ុណ្ណោះ។ រូបបរិវត្តន៍ (transformation) នៃ ជនាមនោសញ្ចេតនា (expression populaire) នេះ ជាការក្លែងជាក់ស្តែងនូវឆន្ទៈប្រជាជន ដើម្បីអ្នកដឹកនាំគណបក្សប្រឆាំងតែមាត់ មួយក្តាប់តូច ស្វែងរកអត្ថប្រយោជន៍ ជាមួយអ្នកកាន់អំណាច។ តែអ្នកដឹកនាំទាំងនោះ ឥតបានយល់ថា អំពើរបស់ខ្លួននេះ មានវិបាកជាមហន្តរាយដល់ដំណើរការលូតលាស់នៃលទ្ធិប្រជាធិបតេយ្យនោះឡើយ។ ទី១ នាំឲអ្នកស្រឡាញ់ជាតិ ដែលគេ ត្រូវចាំបាច់រស់ដើម្បីចិញ្ចឹមជីវិតគ្រួសារ ធ្វើការនៅក្នុងគ្រប់ក្រសួងជាតិ ឋិតក្រោមការគាបសង្កត់នៃគណបក្សកាន់អំណាច លែងហ៊ានកំរើកពីនឹមអំណាចផ្តាច់ការ, ទី២ នាំផ្ទុប់កម្លាំងប្រជាជន ឲកើតចេញបានជាកម្លាំងប្រឆាំងនឹងអំណាចផ្តាច់ការ តាមបែបហឹង្សាក្តី អហឹង្សាក្តី, ទី៣ ជាការលើកទឹកចិត្តដល់គណបក្សកាន់អំណាច ដែលនាំឲគេអាចបន្តនយោបាយហឹង្សាមកលើអ្នកប្រឆាំងតាមទំនើងចិត្ត។ ជាពិសេស គឺនាំឲប្រជាជនអស់សេចក្តីទុកចិត្ត ទៅលើគណបក្សប្រឆាំង ឬ មានការសង្ស័យ ទៅលើសមត្ថភាពរបស់ខ្លួន ក្នុងការតស៊ូដើម្បីសេរីភាព និង យុត្តិធម៌ ព្រោះអ្វីដែលខ្លួនធ្វើគឺវាមិនដែលមានលាភជ័យសោះ, ទី៤ គឺនាំឲសហគមអន្តរជាតិ គេពុំអាចប្រកាន់គោលជំហរការពារអ្វីបាននោះឡើយ ក្រៅពីនាំគ្នាដេកចាំមើលលទ្ធផលនៃការចរចារ របស់ភាគីខ្មែរតែប៉ុណ្ណោះ។

ម្យ៉ាងមួយវិញទៀត ការចាប់ឃុំលោកស្រី មូរ-សុខហួរ និង បេក្ខជនជាប់ឆ្នោតនៃគណបក្សសង្គ្រោះជាតិ បួនរូបទៀត មានលោក ម៉ែន-សុថាវរិន្ទ្រ, កែវ-ភិរម្យ, ហូរ-វ៉ាន់, និង រៀល-ខេមរិន្ទ បញ្ជាក់ឲឃើញកាន់តែច្បាស់ថែមទៀតថា យុទ្ធសាស្ត្រ រកចងសំភារជាមួយគណបក្សកាន់អំណាច របស់គណបក្សសង្គ្រោះជាតិ វាមានវិបាកជាអវិជ្ជមានដូចរៀបរាប់ខាងលើនេះឯងហើយដែលនាំខ្លួនមានស្រយុត (défaillance) ក្នុងគោលជំហររបស់ខ្លួន នៅចំពោះមុខការរំលោភអំណាចពីសំណាក់រាជរដ្ឋាភិបាល ព្រោះអ្នកដឹកនាំឥតមានសេចក្តីក្លាហានផ្តន្ទាទោសដោយចំពោះទៅលើរាជរដ្ឋាភិបាល ដែលជាអ្នកកាន់កាប់អំណាចផ្តាច់ការ។ ការខ្វះសេចក្តីក្លាហាននេះ គឺគ្មានអ្វីក្រៅពីអ្នកដឹកនាំគណបក្សសង្គ្រោះជាតិមួយចំនួន នៅតែចង់រក្សាការរកចងសំភារជាមួយគណបក្សប្រជាជន ដើម្បីស្វែងរកអត្ថប្រយោជន៍សំរាប់ពួកខ្លួនតែប៉ុណ្ណោះ។

ដើម្បីសេចក្ដីសុខ ច្បាស់ជាអ្នកដឹកនាំគិតរកចំណេញទាំងនោះ នឹងមិនហ៊ានទទួលខុសត្រូវលើទង្វើអ្នកគាំទ្រខ្លួននោះដាច់ខាត ដែលជាអ្នកតស៊ូមតិ ហ៊ានពុះពារទាមទារឲបើកលានប្រជាធិបតេយ្យ។ បើការនេះជាការពិតមែន តើពាក្យ «សង្គ្រោះជាតិ» របស់គណបក្ស វាមានន័យបែបណាទៅវិញ? ច្បាស់ជាមានន័យថា អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ កំពុងរំលោភឆន្ទះប្រជាពលរដ្ឋខ្មែរ ដើម្បីបំរើការរំលោភអំណាចរបស់អ្នកដឹកនាំគណបក្សកាន់អំណាច។